# កម្មវិធីដឹកនាំដោយខ្លួនឯង

ការគាំទ្រ ការផ្តល់អំណាច ជម្រើស

**សំណួរដែលសួរញឹកញាប់អំពីកម្មវិធីដឹកនាំដោយអ្នកចូលរួម (Participant Directed Program)**

1. **សំណួរ៖ ប្រសិនបើខ្ញុំចង់ដឹកនាំនាយកដ្ឋានសេវាកម្មអភិវឌ្ឍន៍ DDS របស់ខ្ញុំដោយខ្លួនឯងជាមួយកម្មវិធីដឹកនាំដោយអ្នកចូលរួម តើខ្ញុំនឹងចាប់ផ្តើមដោយរបៀបណា?**
**ចម្លើយ៖** ដើម្បីចុះឈ្មោះនៅក្នុងកម្មវិធី Participant Directed Program (PDP) លោកអ្នកត្រូវទាក់ទងអ្នកសម្របសម្រួលសេវាកម្ម DDS របស់អ្នក។ បុគ្គលម្នាក់ត្រូវតែមានសិទ្ធិទទួលបានសេវាកម្ម DDS របស់មនុស្សពេញវ័យ មានតម្រូវការវាយតម្លៃ និងផ្តល់អាទិភាពសម្រាប់សេវាកម្ម DDS ដោយមានការចាត់ចែងចំណាយដោយឡែក។ លោកអ្នកត្រូវតែមានឆន្ទៈធ្វើការជាមួយអ្នកសម្របសម្រួលសេវាកម្ម/អន្តរការីជួយគាំទ្រសេវាកម្ម DDS តាមតម្រូវការ ដើម្បីស្វែងយល់អំពីទិដ្ឋភាពនៃកម្មវិធី PDP។

2. **សំណួរ៖ តើបុគ្គលម្នាក់អាចចុះឈ្មោះក្នុងកម្មវិធី Participant Directed Program នៅអាយុប៉ុន្មាន?**
**ចម្លើយ៖** តាមធម្មតាសេវាកម្ម DDS របស់មនុស្សពេញវ័យចាប់ផ្តើមនៅអាយុ 22 ឆ្នាំ នៅពេលសេវាកម្មសាលាបញ្ចប់។ បុគ្គលនានាដែលមានសិទ្ធិទទួលបានសេវាកម្ម ASD (សេវាកម្មជំងឺអូទីសឹមដោយគ្មានពិការភាពខាងបញ្ញា) អាចទទួលបានសេវាកម្មនៅពេលពួកគេមានអាយុ 18 ឆ្នាំ ហើយឈប់រៀន។ បុគ្គលនានាដែលបានចុះឈ្មោះក្នុងកម្មវិធី DESE អាចជ្រើសរើសសេវាកម្មផ្ទាល់របស់ពួកគេតាមរយៈកម្មវិធី PDP។ ត្រូវពិភាក្សាអំពីស្ថានភាពផ្សេងទៀតជាមួយអ្នកសម្របសម្រួលសេវាកម្ម ឬការិយាល័យប្រចាំតំបន់របស់អ្នក។

3. **សំណួរ៖ តើអ្វីទៅជាអន្តរការីជួយគាំទ្រ?**
**ចម្លើយ៖** ជាទូទៅអន្តរការីជួយគាំទ្រគឺជាអ្នកសម្របសម្រួលសេវាកម្ម DDS ដែលជួយលោកអ្នកដើម្បីកំណត់ចក្ខុវិស័យ និងតម្រូវការរបស់លោកអ្នក។ ពួកគេនឹងជួយបង្កើតថវិកា និងអភិវឌ្ឍបណ្តាញសេវាកម្ម និងការគាំទ្រ។ អន្តរការីជួយគាំទ្រសេវាកម្ម DDS ជួយផ្នែកទស្សនៈវិស័យជាច្រើននៃកម្មវិធី (Participant Directed Program របស់ពួកគេ។

4. **សំណួរ៖ តើសេវាកម្មគ្រប់គ្រងហិរញ្ញវត្ថុជាអ្វី ហើយតើខ្ញុំនឹងប្រើប្រាស់សេវាកម្មជាមួយកម្មវិធី Participant Directed Program ដោយរបៀបណា?**
**ចម្លើយ៖** សេវាកម្ម DDS មានកិច្ចសន្យាជាមួយសេវាកម្មគ្រប់គ្រងហិរញ្ញវត្ថុ ដែលហៅថា **Public Partnerships LLC (PPL)**។ PPL ផ្តល់ជូនការទទួលខុសត្រូវផ្នែកសារពើពន្ធដោយធានាថាការបង់ប្រាក់គឺស្របទៅនឹងអ្វីដែលសេវាកម្ម DDS បានអនុញ្ញាតនិងគោរពតាមតម្រូវការទាមទាររបស់រដ្ឋ និងសហព័ន្ធ។ ពួកគេចេញមូលប្បទានប័ត្រប្រាក់បៀវត្សរ៍ និង/ឬធ្វើការទូទាត់ប្រាក់រៀងរាល់ពីរសប្តាហ៍ម្តង ពួកគេអនុវត្តការត្រួតពិនិត្យ CORI និងការពិនិត្យសាវតារថ្នាក់ជាតិ, ដំណើរការកម្មវិធីបុគ្គលិក កាត់ទុកពន្ធសមរម្យនៅថ្នាក់រដ្ឋ និងសហព័ន្ធ ចេញរបាយការណ៍ W-2 និង 1099 ក្នុងខែមករា ផ្តល់របាយការណ៍ស្ថានភាពប្រាក់បៀវត្សរ៍ពេញមួយឆ្នាំ និងរៀបចំសំណងគ្រោះថ្នាក់ការងារសម្រាប់បុគ្គលិក។

5. **សំណួរ៖ តើបុគ្គលិករបស់ខ្ញុំមានពន្ធកាត់ទុកពីប្រាក់បៀវត្សរ៍របស់ពួកគេឬទេ?**
**ចម្លើយ៖** បាទ/ចាស ពន្ធត្រូវបានកាត់ទុកសម្រាប់បុគ្គលិក ដែលរួមមាន៖ សន្តិសុខសង្គម, កម្មវិធី Medicaid (FICA) និងពន្ធលើប្រាក់ចំណូលរដ្ឋ និងសហព័ន្ធ ត្រូវបានកាត់ទុកពីប្រាក់បៀវត្សរ៍របស់បុគ្គលិកម្នាក់ៗ។ PPL នឹងរៀបចំ និងផ្ញើរបាយការណ៍ប្រាក់ឈ្នួល W-2 ទៅបុគ្គលិកម្នាក់ៗក្នុងខែមករា។

6. **សំណួរ៖ តើខ្ញុំត្រូវស្វែងរកបុគ្គលិកមកបម្រើការងារដោយរបៀបណា?**
**ចម្លើយ៖** ប្រជាពលរដ្ឋជាច្រើនមានភាពច្នៃប្រឌិត និងស្វែងរកបុគ្គលិកនៅក្នុងបណ្តាញប្រចាំថ្ងៃរបស់ពួកគេ។ វាអាចជាអ្នកណាម្នាក់ដែលគេស្គាល់នៅក្នុងប្រព័ន្ធសាលារៀន អ្នកជិតខាង មិត្តភក្តិរបស់គ្រួសារ ឬបុគ្គលម្នាក់ដែលត្រូវបានរកឃើញតាមរយៈការផ្សាយពាណិជ្ជកម្ម ឬគេហទំព័រអនឡាញ ដូចជា RewardingWork.org, Care.com, Indeed.com និងអ្នកដទៃ។ ការប្រាស្រ័យទាក់ទងដោយពិភាក្សាជាមធ្យោបាយបញ្ជូនព័ត៌មាននិងការបើកចំហរដើម្បីចែករំលែកដំណឹងការងារគឺមានប្រយោជន៍ណាស់។

7. **សំណួរ៖ តើខ្ញុំអាចជួលសមាជិកគ្រួសារឱ្យបម្រើការងារជាបុគ្គលិកបានទេ?**
**ចម្លើយ៖** អ្នកចូលរួមមិនអាចជួលប្ដីឬប្រពន្ធឱ្យបម្រើការងាររបស់ពួកគេ ឬអ្នកអាណាព្យាបាលស្របច្បាប់ឱ្យបម្រើការងាររបស់ពួកគេសម្រាប់សេវាកម្មណាមួយឡើយ។ សមាជិកគ្រួសារផ្សេងទៀតអាចជួលឱ្យបម្រើការងារជាបុគ្គលិក និងអាចបង់ប្រាក់សម្រាប់ការផ្ដល់សេវាកម្មជាក់លាក់លុះត្រាតែពួកគេបំពេញតាមតម្រូវការទាមទារជាក់លាក់។ លោកអ្នកត្រូវតែពិភាក្សាជាមួយអន្តរការីជួយគាំទ្រសេវាកម្ម DDS របស់អ្នក អំពីការជួលសមាជិកគ្រួសារផ្សេងទៀតឱ្យបម្រើការងារសម្រាប់ការណែនាំជាក់លាក់។

8. **សំណួរ៖ តើបុគ្គលិកត្រូវបំពេញអ្វីខ្លះ ដើម្បីជួលបុគ្គលិកឱ្យបម្រើការងារ?**
**ចម្លើយ៖** ពួកគេត្រូវតែបំពេញពាក្យសុំការងារដែលរួមមាន CORI និងសំណើពិនិត្យសារតារថ្នាក់ជាតិ។ ការពិនិត្យទាំងនេះត្រូវតែបំពេញ និងអនុម័តមុនពេលពួកគេអាចធ្វើការងារ។

9. **សំណួរ៖ តើបុគ្គលិករបស់ខ្ញុំអាចធ្វើការមុនពេលពួកគេអនុវត្តការពិនិត្យ CORI របស់ពួកគេឬទេ?**
**ចម្លើយ៖** បុគ្គលិកមិនអាចចាប់ផ្ដើមធ្វើការមុនការអនុម័តពី CORI ហើយ PPL នឹងមិនចេញការទូទាត់ប្រាក់សម្រាប់ពេលវេលាដែលបានដាក់ជូនពិនិត្យមុនពេលការអនុម័ត CORI ឡើយ។ វិធាននេះគឺដើម្បីការពារលោកអ្នកនិងគ្រួសាររបស់អ្នកឱ្យសមស្របពីការជួលនរណាម្នាក់ឱ្យបម្រើការងារដែលមិនអាចបំពេញតាមស្តង់ដាររដ្ឋ ដើម្បីផ្ដល់សេវាកម្មដែលអាចមាននៅក្នុងកម្មវិធីនេះ។ តម្រូវឱ្យមានការពិនិត្យសារតារថ្នាក់ជាតិផងដែរ នេះជាការពិនិត្យស្នាមមេដៃឡើងវិញនៅកម្រិតសហព័ន្ធ។

10. **សំណួរ៖ ចុះបើបុគ្គលិករបស់ខ្ញុំមិនអាចមកធ្វើការមួយថ្ងៃ?**
ចម្លើយ៖ វាមានសារៈសំខាន់ណាស់ក្នុងការរៀបចំផែនការបម្រុងទុកជាផ្នែកមួយនៃកម្មវិធី Participant Directed Program ក្នុងករណីបុគ្គលិកមិនអាចមាន។  ការជួលបុគ្គលិកជាច្រើននាក់ គឺជាការគិតពិចារណា។

11. **សំណួរ៖ តើថវិកាកម្មវិធីនេះ ត្រូវបានកំណត់យ៉ាងដូចម្តេច?**
**ចម្លើយ៖** ថវិកានីមួយៗផ្អែកលើតម្រូវការពិសេសរបស់បុគ្គល ការគាំទ្រដែលត្រូវការ និងភាពញឹកញាប់នៃសេវាកម្មទាំងនេះ។ នាយកប្រចាំតំបន់នៃសេវាកម្ម DDS កំណត់ចំនួនថវិកាទូទៅដោយផ្អែកលើព័ត៌មានពីការវាយតម្លៃ និងធនធានដែលអាចមាន។ ថវិកាដែលបានអនុម័តដោយសេវាកម្ម DDS គឺចាំបាច់សម្រាប់ការចុះឈ្មោះក្នុងកម្មវិធី Participant Directed Program។

12. **សំណួរ៖ តើអ្នកចូលរួមម្នាក់នឹងអាចតាមដានថវិការបស់ខ្លួនយ៉ាងដូចម្តេច?**
**ចម្លើយ៖** អ្នកចូលរួមនឹងមានសិទ្ធិចូលមើលថវិការបស់ពួកគេតាមអនឡាញក្នុងពេលជាក់ស្តែងតាមរយៈ **PPL Web Portal**។ អ្នកចូលរួមក៏អាចពិនិត្យមើលឡើងវិញ និងពិភាក្សាអំពីថវិការបស់ពួកគេជាមួយអន្តរការីជួយគាំទ្រសេវាកម្ម DDS របស់ពួកគេផងដែរ។

13. **សំណួរ៖ ប្រសិនបើមានថវិកានៅសល់នៅចុងឆ្នាំសារពើពន្ធ តើមានអ្វីកើតឡើង?**
**ចម្លើយ៖** ថវិកានេះត្រូវបានរៀបចំឡើងសម្រាប់ឆ្នាំសារពើពន្ធ (ថ្ងៃទី 1 ខែកក្កដា ដល់ថ្ងៃទី 30 ខែមិថុនា) ដើម្បីផ្ដល់សេវាកម្ម និងការគាំទ្រដែលបុគ្គលត្រូវការ។ មូលនិធិដែលមិនបានប្រើ មិនអាចអនុវត្តនៅឆ្នាំសារពើពន្ធបន្ទាប់ ឬប្រគល់ជូនបុគ្គលនោះដោយផ្ទាល់បានទេ។

14. **សំណួរ៖ តើអ្នកចូលរួមអាចទិញ "ទំនិញ និងសេវាកម្ម" ជាឧទាហរណ៍សមាជិកភាព ឬសកម្មភាព ថ្នាក់រៀន ជាដើមបានដែរឬទេ?**
**ចម្លើយ៖** បាទ/ចាស ទំនិញ និងសេវាកម្មអាចទិញ ប៉ុន្តែត្រូវពិភាក្សាជាមុនជាមួយអន្តរការីជួយគាំទ្រសេវាកម្ម DDS របស់អ្នក។ សំណើទូទាត់ប្រាក់ ឬសំណង នឹងត្រូវបង់ប្រាក់ដោយវិក្កយបត្រ PPL និង/ឬបង្កាន់ដៃបង់ប្រាក់ PPL ដែលបានបំពេញ។ ជម្រើសនេះ ត្រូវតែអនុវត្តតាមការណែនាំនិងនីតិវិធីរបស់សេវាកម្ម DDS ដែលបញ្ជាក់អំពីប្រភេទនៃការចំណាយដែលអាចអនុញ្ញាតបាន និងមិនអាចអនុញ្ញាតបាន តម្រូវការទាមទារនិងនីតិវិធីនៃការអនុម័តមុន និងតម្រូវការទាមទាររាយការណ៍ និងការត្រួតពិនិត្យផ្សេងទៀត។

15. **សំណួរ៖ តើមានជម្រើសដឹកនាំដោយខ្លួនឯងផ្សេងទៀត ក្រៅពីកម្មវិធី Participant Directed Program ដែរឬទេ?**
**ចម្លើយ៖** បាទ/ចាស គំរូកម្មវិធី Agency with Choice Model ផ្ដល់ជូនសមត្ថភាពដូចគ្នា ដើម្បីកំណត់ជាលក្ខណៈបុគ្គលនៃការគាំទ្រនិងសកម្មភាពនានា ប៉ុន្តែដោយមានជំនួយពីទីភ្នាក់ងារផ្ដល់សេវាកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលមានចំណេះដឹងអំពីការសម្រេចចិត្តចុងក្រោយដោយខ្លួនឯង។ ជម្រើសមួយទៀតគឺត្រូវមានការរួមបញ្ចូលសេវាកម្មបែបប្រពៃណី និងកម្មវិធី Participant Directed Program។

## នាយកដ្ឋានសេវាកម្មអភិវឌ្ឍន៍នៃរដ្ឋ MASSACHUSETTS